**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# សុន្ទរកថាស្វាគមន៍ និងរបាយការណ៍សង្ខេប
# ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា
# ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ បណ្ដាញសាកលវិទ្យាល័យសាយប័រកម្ពុជា

វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, ថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២៤

*សូមគោរព៖*

**សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់បំផុត !

ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី
ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ
ឯកឧត្តម លោកជំទាវ លោក លោកស្រីសាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក
ក្មួយៗនិស្សិតទាំងអស់ ជាទីគោរព និងជាទីស្រឡាញ់!

ថ្ងៃនេះជាទិវាប្រកបដោយនក្ខត្តឫក្ស ដែលយើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំនៃក្រសួងអប់រំ យុវជន និងកីឡា គ្រឹះស្ថានឧត្តមសិក្សា សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិក និស្សិត រួមជាមួយអង្គពិធីទាំងមូល មានកិត្តិយសសូមទទួលស្វាគមន៍ និងសូមធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្ដៅជូនចំពោះវត្តមានដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង **លោកជំទាវបណ្ឌិត** ដែលបានអញ្ជើញចូលរួមជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់បណ្ដាញសាកលវិទ្យាល័យសាយប័រកម្ពុជា និងសមិទ្ធផលនៃការបណ្ដុះបណ្ដាលផ្នែកបច្ចេកវិទ្យាឌីជីថលនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា នាថ្ងៃនេះ។

តាងនាមក្រសួងអប់រំ យុវជន និងកីឡា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមគោរពថ្លែងអំណរគុណជាអនេកប្បការ និងសូមសម្ដែងគារវកិច្ចស្វាគមន៍យ៉ាងកក់ក្ដៅបំផុត និងប្រកបដោយកតញ្ញុតាធម៌ដ៏ជ្រាលជ្រៅចំពោះ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតយកឱកាសដ៏មមាញឹក និងមានតម្លៃ អញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីដ៏ឱឡារិកនេះ។ វត្តមានដ៏ឧត្តុង្គឧត្តមរបស់ **សម្ដេចធិបតីនាយករដ្ឋមន្ត្រី** ពិតជាឆ្លុះបញ្ចាំងអំពីការយកចិត្តទុកដាក់ខ្ពស់

ចំពោះវិស័យអប់រំ និងជាការលើកទឹកចិត្តដល់ថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ របស់ក្រសួងអប់រំ យុវជន និងកីឡា ឱ្យកាន់តែមានភាពកក់ក្តៅទ្វេឡើងថែមទៀត ក្នុងការចូលរួមចំណែកអភិវឌ្ឍវិស័យអប់រំនៅកម្ពុជា។

ក្នុងឱកាសដ៏មហាប្រសើរនេះ ខ្ញុំបាទមានកិត្តិយសសូមការអនុញ្ញាតរាយការណ៍ជូន **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ព្រមទាំងអង្គពិធីអំពី សមិទ្ធផលការងារសំខាន់ៗរបស់អនុវិស័យឧត្តមសិក្សា ការបង្កើតបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាពិសេសវឌ្ឍនភាពក្នុងការបណ្តុះបណ្តាលមុខជំនាញបច្ចេកវិទ្យាឌីជីថល ដែលមានខ្លឹមសារដូចតទៅ៖

## ១. លទ្ធផលនៃកំណែទម្រង់ឧត្តមសិក្សា (២០១៣-២០២៤)

ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សេដ្ឋកិច្ចកម្ពុជា ក្នុងការធ្វើពិពិធកម្ម និងការអនុវត្តយុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ នៅត្រង់មុំទី១នៃបញ្ចកោណទី១៖ ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា និងបញ្ចកោណទី៥៖ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ជាពិសេស ការកសាងមូលធនមនុស្សដែលមានជំនាញឌីជីថល តាមរយៈការធ្វើទំនើបកម្ម និងការធ្វើសុវឌ្ឍិកម្មកម្មវិធីសិក្សា និងកម្មវិធីបណ្តុះបណ្តាលជំនាញឌីជីថល និងការលើកកម្ពស់អក្ខកម្មឌីជីថល កំណែទម្រង់ឧត្តមសិក្សាបានផ្តោតលើ៖

### សសរស្តម្ភទី១៖ ការកែលម្អសមត្ថភាពបង្រៀន និងរៀន

<u>**១. កម្មវិធីភាពជាដៃគូជាមួយសាកលវិទ្យាល័យ**</u>៖ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈនិងឯកជនចំនួន ១១ បាននិងកំពុងបន្តអនុវត្តកិច្ចព្រមព្រៀងភាពជាដៃគូជាមួយសាកលវិទ្យាល័យនៅក្រៅប្រទេសចំនួន ១៧ និងគ្រឹះស្ថានឧត្តមសិក្សាក្នុងស្រុកចំនួន ៤ ក្នុងការកែលម្អ និងការរៀបចំកម្មវិធីសិក្សា វិធីសាស្ត្របង្រៀន វិធីសាស្ត្រវាយតម្លៃ និងការលើកកម្ពស់គុណវុឌ្ឍិគ្រូ និងបុគ្គលិកកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត។

ជាលទ្ធផល៖ ១).កម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រថ្មីត្រូវបានបង្កើតឡើង និងកែលម្អមានចំនួន ៧៩ ២).បុគ្គលិកអប់រំនៅតាមគ្រឹះស្ថានឧត្តមសិក្សាចំនួន ១៩៩រូប កំពុងបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត និងមន្ត្រី ២៧រូប បានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ៣).បុគ្គលិកអប់រំចំនួន ៧៨៦រូប បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញរយៈពេលខ្លី និង ៤).បន្ទប់ពិសោធសម្រាប់បង្រៀន និងរៀនចំនួន ៩០ បានត្រូវសាងសង់និងជួសជុល ។

**ដើម្បីលើកកម្ពស់គុណភាព និងភាពឆ្លើយតបនៅឧត្តមសិក្សា** ជាពិសេសដើម្បីធានាបាននូវគុណភាពនៃការអប់រំនិស្សិតឱ្យមានចំណេះដឹង និងជំនាញស្របតាមស្តង់ដាតិ និងអន្តរជាតិ ក្រសួងបានធ្វើទំនើបកម្មកម្មវិធីអប់រំ តាមរយៈការរៀបចំ៖ ១).ក្របខ័ណ្ឌអភិវឌ្ឍកម្មវិធីអប់រំតាមបែបការអប់រំផ្អែកលើលទ្ធផល (Outcome-based Education) ២).គោលការណ៍ណែនាំស្តីពី

បរិវត្តកម្មកម្មវិធីសិក្សា ៣).គោលការណ៍ណែនាំស្តីពីគរុកោសល្យនវានុវត្តន៍ និង ៤).គោលការណ៍ណែនាំស្តីពីការវាយតម្លៃលទ្ធផលសិក្សា។

**២. កម្មវិធីភាពជាដៃគូក្នុងស្រុកសម្រាប់ការអប់រំវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា៖** គ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន ៥ បានបណ្តុះបណ្តាលទាំងទ្រឹស្តី និងការអនុវត្តលើបំណិនកសិកម្ម និងបច្ចេកវិទ្យាចំនួន ២១ ដល់គ្រូបង្គោលចំនួន ៣៩១នាក់ ដែលមកពីសាលាមធ្យមសិក្សាចំនួន ១០២។ គ្រូបង្គោលបំណិនចំនួន ៣៦១នាក់ បានផ្តល់ការបណ្តុះបណ្តាលបំណិនបន្តទៅដល់សិស្សមធ្យមសិក្សាចំនួន ១៧,១២១នាក់ បានរៀបចំផែនការអាជីវកម្មចំនួន ៣១០ និងមានសិស្សចំនួន ២,៤៨៩នាក់ បានសន្សំប្រាក់ពីការអនុវត្តបំណិន និងសិស្សចំនួន ៣,១៧២នាក់ បានបង្កើនលទ្ធផលនៃការសិក្សា (ដោយទទួលបាននិទ្ទេសល្អ និងល្អប្រសើរ) ក្នុងការប្រឡងតេស្តស្តង់ដានៅសាលាមធ្យមសិក្សារបស់ពួកគេ។

**៣. ការគាំទ្រគ្រឹះស្ថានឧត្តមសិក្សាឯកជន៖** ១).កម្មវិធីសិក្សាចំនួន ១២ ត្រូវបានរៀបចំក្រោមកម្មវិធីភាពជាដៃគូជាមួយគ្រឹះស្ថានឧត្តមសិក្សាក្រៅប្រទេស ២).ប្លង់មេរៀនលម្អិតចំនួន ២៣៧ ត្រូវបានកែសម្រួលនិងបង្កើតថ្មី ៣).បានចងក្រងសៀវភៅសិក្សាគោលចំនួន ១៤៦, ៤). បានទិញសៀវភៅសិក្សាគោល និងសៀវភៅជាឯកសារយោងចំនួន ៤៦៤ សម្រាប់និស្សិតសិក្សាស្រាវជ្រាវ ៥).បានជួសជុលនិងកែលម្អបន្ទប់ពិសោធន៍ចំនួន ១៧, ៦).គ្រូបង្រៀននិងបុគ្គលិកគាំទ្រ ២៤នាក់ បានចុះឈ្មោះចូលរៀន ដើម្បីបង្កើនគុណវុឌ្ឍិកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត ៧).គ្រូបង្រៀននិងបុគ្គលិកគាំទ្រចំនួន ២២៩នាក់ បានចូលរួមវគ្គបណ្តុះបណ្តាលនានា ដើម្បីបំប៉នបន្ថែមទៅលើជំនាញដែលមានស្រាប់។

**៤. ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរឹង៖** ការកសាងហេដ្ឋារចនាសម្ព័ន្ធ និងមូលដ្ឋានសម្ភាររូបវន្តនៅតាមគ្រឹះស្ថានឧត្តមសិក្សាបានកើនឡើងក្នុងរយៈពេល ១០ឆ្នាំ ចុងក្រោយនេះ ដើម្បីគាំទ្រដល់ការការរៀននិងបង្រៀន និងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដោយផ្តោតលើគ្រឹះស្ថានឧត្តមសិក្សាគោលដៅចំនួន ៦ ដែលផ្សារភ្ជាប់ទៅនឹងប៉ូលសេដ្ឋកិច្ចសំខាន់ៗរបស់ប្រទេស។ សមិទ្ធផលទទួលបានរួមមាន៖

១). មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការរវាងសាកលវិទ្យាល័យ និងឧស្សាហកម្ម (University-Industry Cooperation Center) របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដែលមានទីតាំងនៅជិតកីឡដ្ឋានមរតកតេជោ

២). មជ្ឈមណ្ឌលភ្ញាស់ធុរកិច្ច និងអន្តេវាសិកដ្ឋានរបស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៣). អគារមជ្ឈមណ្ឌលស្រាវជ្រាវ និងបណ្តុះបណ្តាលកសិកម្ម និងអគារសិក្សាអន្តេវាសិកដ្ឋានរបស់សាកលវិទ្យាល័យជាតិបាត់ដំបង

៤).អន្តេវាសិកដ្ឋាន និងអគារពហុបំណងរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៥). អគារសិក្សា និងមជ្ឈមណ្ឌលភ្ញាស់ធុរកិច្ចរបស់សាកលវិទ្យាល័យស្វាយរៀង

៦). វិទ្យាស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន និងមហាវិទ្យាល័យសេដ្ឋកិច្ចឌីជីថលរបស់សាកលវិទ្យាល័យជាតិគ្រប់គ្រង

៧). មជ្ឈមណ្ឌលអប់រំ និងបណ្តុះបណ្តាលជាតិជាស៊ីមកំចាយមារ នៅសាកលវិទ្យាល័យជាតិ ជាស៊ីម កំចាយមារ

៨). អន្តេវាសិកដ្ឋាននៅតាមគ្រឹះស្ថានឧត្តមសិក្សា ៥ (កំពុងសាងសង់នៅសាកល-វិទ្យាល័យភូមិន្ទភ្នំពេញ, សាកលវិទ្យាល័យជាតិបាត់ដំបង, សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងសាកលវិទ្យាល័យក្រចេះ)

៩). ការសាងសង់ និងកែលម្អកសិដ្ឋាន និងស្ថានីយកសិកម្មចំនួន ១៣ នៅគ្រឹះស្ថានឧត្តមសិក្សា ៩

១០). ការជួសជុលកែលម្អថ្នាក់រៀន បន្ទប់ពិសោធន៍ និងការបំពាក់សម្ភារបរិក្ខារនៅតាមគ្រឹះស្ថានឧត្តមសិក្សារដ្ឋ និងឯកជន ចំនួន១២ បន្ទប់ស្ទូឌីយ៉ូចំនួន ៥ ត្រូវបានរៀបចំ និងបំពាក់សម្ភារៈឧបករណ៍ឌីជីថលសម្រាប់ការថត និងផលិតមេរៀនសម្រាប់ការរៀន និងបង្រៀនតាមឌីជីថល។

## សសរស្តម្ភទី២៖ ការកែលម្អសមត្ថភាពស្រាវជ្រាវលើផ្នែកវិទ្យាសាស្ត្របច្ចេកវិទ្យា និងកសិកម្ម

ការស្រាវជ្រាវ និងអភិវឌ្ឍន៍នៅអនុវិស័យឧត្តមសិក្សាកម្ពុជាមានការវិវត្តគួរឱ្យកត់សម្គាល់ និងមានសមិទ្ធផល ដូចខាងក្រោម៖

មជ្ឈមណ្ឌលស្រាវជ្រាវឧត្តមភាពចំនួន៤ ត្រូវបានបង្កើតឡើង រួមមាន៖ មជ្ឈមណ្ឌលឧត្តមភាពសម្រាប់នវានុវត្តន៍ការរៀន និងបង្រៀន មានទីតាំងនៅសាកលវិទ្យាល័យភូមិន្ទភ្នំពេញ មជ្ឈមណ្ឌលឧត្តមភាពប្រពលវប្បកម្មកសិកម្មនិរន្តរភាពនិងអាហារូបត្ថម្ភ មានទីតាំងនៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម មជ្ឈមណ្ឌលឧត្តមភាពសម្រាប់ការស្រាវជ្រាវស្ថានប្រព័ន្ធជលសាស្ត្រ មានទីតាំងនៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា និងមជ្ឈមណ្ឌលឧត្តមភាពនៃការស្រាវជ្រាវ អភិវឌ្ឍន៍ និងនវានុវត្តន៍ មានទីតាំងនៅសាកលវិទ្យាល័យជាតិគ្រប់គ្រង។

ក្រសួងបានវិនិយោគលើគម្រោងស្រាវជ្រាវចំនួន ៩៨គម្រោង ក្នុងនោះគម្រោងស្រាវជ្រាវសហការ និងផ្សារភ្ជាប់នឹងវិស័យឯកជនចំនួន ៤៤គម្រោង ដែលមានអ្នកស្រាវជ្រាវសរុបប្រមាណ ៥០០នាក់ចូលរួមអនុវត្ត។ ផលិតផលកសិកម្ម និងបច្ចេកវិទ្យា (Products) ចំនួន

២២ ត្រូវបានផលិត និងផលិតផលគំរូ(prototypes) ចំនួន ៤២ ត្រូវបានផលិតចេញពីគម្រោងស្រាវជ្រាវ ២៦។

ចំនួនបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រ ដែលទទួលស្គាល់ដោយមូលទិន្នន័យស្កូភើស (Scopus database) ដែលជាមូលទិន្នន័យធំបំផុតរបស់ពិភពលោក បានកើនឡើងពី ២៧៧អត្ថបទ ក្នុងឆ្នាំ២០១៣ ដល់ចំនួន ៨៥៣អត្ថបទ ក្នុងឆ្នាំ២០២៣។ ចំនួនទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រក្នុងស្រុកបានកើនឡើងពី ១៣ ក្នុងឆ្នាំ២០១២ រហូតដល់ចំនួន ៥២ នៅត្រឹមពាក់កណ្ដាលឆ្នាំ២០២៤ ក្នុងនោះទស្សនាវដ្ដីស្រាវជ្រាវវិទ្យាសាស្ត្រក្នុងស្រុកចំនួន ២ បានទទួលស្គាល់ដោយ ASEAN Citation Index ដូចជា Cambodian Journal of Natural History និង Journal of Management, Economics, and Industrial Organization។ អត្ថបទស្រាវជ្រាវបែបវិទ្យាសាស្ត្រចំនួន ៧៧ ត្រូវបានបោះពុម្ពនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវអន្តរជាតិ និងអត្ថបទ ២០ ទៀតបានបោះពុម្ពនៅក្នុងទស្សនាវដ្ដីស្រាវជ្រាវជាតិ។

អ្នកស្រាវជ្រាវចំនួន ២០០នាក់ មានសមត្ថភាពក្នុងការគ្រប់គ្រងគម្រោងស្រាវជ្រាវ និងបានចាប់ផ្ដើមផ្សារភ្ជាប់នឹងឧស្សាហកម្ម។ ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្នែម (CJES) ត្រូវបានបង្កើតនៅឆ្នាំ២០២២។ នៅឆ្នាំ២០២៣ ទស្សនាវដ្ដីនេះបានបោះពុម្ពអត្ថបទចំនួន១៦ជាភាសាខ្មែរ ក្នុងនោះផ្នែកអប់រំចំនួន៨ ផ្នែកកសិកម្មចំនួន៦ និងផ្នែកស្នែមចំនួន ២។

ក្រសួងបានតែងតាំងឋានៈសាស្ត្រាចារ្យក្នុងវិស័យអប់រំលើកដំបូងចំនួន ៣២៨នាក់ ក្នុងនោះសាស្ត្រាចារ្យ ៣២រូប សាស្ត្រាចារ្យរង ៥៨នាក់ និងសាស្ត្រាចារ្យជំនួយ ២៣៨នាក់ មកពីគ្រឹះស្ថានឧត្តមសិក្សាចំនួន ៩។

## សសរស្ដម្ភទី៣៖ ការកែលម្អប្រព័ន្ធអភិបាលកិច្ច

ក្រសួងអប់រំ យុវជន និងកីឡាបានអនុម័តគោលនយោបាយធំៗ និងមានសមិទ្ធផល ដូចខាងក្រោម៖

គោលនយោបាយស្ដីពីចក្ខុវិស័យឧត្តមសិក្សា ២០៣០ មានគោលបំណងដើម្បីជានាសមធម៌ក្នុងការចូលរៀនរបស់និស្សិត តាមរយៈការបង្កើនចំនួនអាហារូបករណ៍ថ្នាក់ជាតិសម្រាប់សិស្សនារី សិស្សអាទិភាព សិស្សមកពីគ្រួសារក្រីក្រ និងនិស្សិតមកពីតំបន់ដាច់ស្រយាល។ គោលនយោបាយនេះក៏បានផ្ដោតទៅលើការលើកកម្ពស់គុណភាព ប្រសិទ្ធភាព ការគ្រប់គ្រងនៅឧត្តមសិក្សា និងយន្តការចាំបាច់នានា ដើម្បីគាំទ្រដល់ប្រព័ន្ធនៅឧត្តមសិក្សា និងការអភិវឌ្ឍធនធានមនុស្ស ដែលនឹងរួមចំណែកយ៉ាងពេញលេញដល់ការអភិវឌ្ឍប្រទេសជាតិ។

ផែនទីបង្ហាញផ្លូវនៅឧត្តមសិក្សាកម្ពុជា ឆ្នាំ២០៣០ និងក្រោយឆ្នាំ២០៣០ បានកំណត់ពីគោលដៅសំខាន់ៗចំនួន ៤ ដែលអនុវិស័យឧត្តមសិក្សាត្រូវដោះស្រាយរួមមាន ១).គុណភាព និងភាពឆ្លើយតបឧត្តមសិក្សាចំពោះការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ២).សមធម៌នៃការចូលរៀននៅឧត្តមសិក្សាឱ្យកាន់តែច្រើន ៣).អន្តរជាតូបនីយកម្មឧត្តមសិក្សាកម្ពុជា ៤).ការពង្រឹងអភិបាលកិច្ចនិងហិរញ្ញវត្ថុនៅឧត្តមសិក្សា។

គោលនយោបាយស្តីពីអភិបាលកិច្ច និងហិរញ្ញប្បទាននៅឧត្តមសិក្សាកម្ពុជា ផ្តោតលើការបង្កើតវិធានការកំណែទម្រង់យុទ្ធសាស្ត្រដែលមានលក្ខណៈទូលំទូលាយ ក្នុងការលើកកម្ពស់អភិបាលកិច្ច និងហិរញ្ញប្បទាននៅឧត្តមសិក្សា ទាំងនៅកម្រិតប្រព័ន្ធ និងកម្រិតស្ថាប័ន។

ការពង្រឹងអភិបាលកិច្ចគ្រឹះស្ថានឧត្តមសិក្សា ផ្តោតលើការផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ដើម្បីជានានូវតម្លាភាព និងគណនេយ្យភាពពេញលេញ ក្នុងការគ្រប់គ្រងទាំងបច្ចេកទេស និងហិរញ្ញវត្ថុ។ បច្ចុប្បន្ននេះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន ១៦ ត្រូវបានប្រែក្លាយជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល ក្នុងនោះ គ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡាមានចំនួន ៦។ គ្រឹះស្ថានឧត្តមសិក្សាចំនួន៤៩ បានចូលរួមអនុវត្តប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង។ ជាមួយគ្នានេះ ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុងកំពុងត្រូវបានកែលម្អ ស្របតាមប្រព័ន្ធធានាគុណភាពអប់រំរបស់អាស៊ាន (AUN-QA)។ គ្រឹះស្ថានឧត្តមសិក្សាចំនួន ៣ (វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងវិទ្យាស្ថានខេមរអេដ) មានកម្មវិធីមួយចំនួនត្រូវបានវាយតម្លៃ និងទទួលស្គាល់គុណភាពកម្រិតតំបន់ និងអន្តរជាតិ។

ប្រព័ន្ធ និងគោលការណ៍ចាំបាច់មួយចំនួនត្រូវបានបង្កើត និងដាក់ឱ្យអនុវត្ត រួមមាន៖ ១). ប្រព័ន្ធធានាគុណភាពអប់រំផ្ទៃក្នុង ២).ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ៣).សៀវភៅប្រតិបត្តិស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ ៤).ប្រកាសស្តីពីការគ្រប់គ្រងធនធានមនុស្សសម្រាប់គ្រឹះស្ថានសាធារណៈរដ្ឋបាល ៥).សេចក្តីណែនាំស្តីពីការសិក្សាស្ថានភាពនិស្សិតក្រោយបញ្ចប់ការសិក្សា ៦).សេចក្តីណែនាំស្តីពីការតាំរបស់និស្សិតនៅតាមគ្រឹះស្ថានឧត្តមសិក្សា ៧).ក្របខណ្ឌអភិវឌ្ឍធនធានមនុស្ស ៨).ផែនការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ៩).យុទ្ធសាស្ត្រអនុវិស័យឧត្តមសិក្សា ១០).យុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សា ១១).សៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា និង ១២). បណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា។

## ២. សមិទ្ធផលក្នុងការផ្តល់សេវាអប់រំឧត្តមសិក្សា

ចំនួនគ្រឹះស្ថានឧត្តមសិក្សាទូទាំងប្រទេសបានកើនឡើងពី ១០៥ នៅឆ្នាំ ២០១៣ ដល់ចំនួន ១៨៩គ្រឹះស្ថានក្នុងឆ្នាំ២០២៣ និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងចំនួន១៧ ក្នុងនោះគ្រឹះស្ថានឧត្តមសិក្សាស្ថិតក្រោមក្រសួងអប់រំ យុវជន និងកីឡាមានចំនួន៨៤ ។

គ្រូបង្រៀនឧត្តមសិក្សាបានកើនពី ១១,៣៦២ នាក់ ក្នុងឆ្នាំ២០១៤ ដល់ ១៧,១២០នាក់ ក្នុងឆ្នាំ២០២៣ ក្នុងនោះគ្រូមានសញ្ញាបត្របរិញ្ញាបត្រចំនួន ២៨ ភាគរយ បរិញ្ញាបត្រជាន់ខ្ពស់ចំនួន ៦០ ភាគរយ និងបណ្ឌិតមានចំនួន ១,៩៦៨ នាក់ ស្មើ ១១.៥ ភាគរយ។

ចំនួននិស្សិតឧត្តមសិក្សាកើនឡើង ១០ភាគរយ ពីចំនួន ២៥៧,៤៧០នាក់ នៅឆ្នាំសិក្សា ២០១២-២០១៣ ដល់ ២៨៤,៥៩៩នាក់ ស្រី១៤៨,៧៥៧នាក់ (បរិញ្ញាបត្ររង ៣៣,០៨១ នាក់ បរិញ្ញាបត្រ ២៣៧,២៤៣នាក់ បរិញ្ញាបត្រជាន់ខ្ពស់ ១៣,០០៨នាក់ និងបណ្ឌិត ១,៣៣០ នាក់) ក្នុងឆ្នាំសិក្សា២០២២-២០២៣។

ក្នុងឆ្នាំ២០២៣ និស្សិតអាហារូបករណ៍ក្នុងស្រុក (បរិញ្ញាបត្ររងនិងបរិញ្ញាបត្រ) មានចំនួន ៣៣,៥៧៤នាក់ ស្មើនឹង ១២.៤ភាគរយ បើធៀបនឹងចំនួននិស្សិតកំពុងសិក្សាសរុបកម្រិតបរិញ្ញាបត្ររងនិងបរិញ្ញាបត្រ ។

និស្សិតចំនួន ៦,២៥៣នាក់ បានទទួលអាហារូបករណ៍ទៅសិក្សានៅបរទេស (១៦ ប្រទេស) ក្នុងនោះទៅសិក្សានៅថៃ ១,៦០៧នាក់ ស្រី ៦៣៨, ចិន ១,៥៥៣នាក់ ស្រី ៣៩១ នាក់, វៀតណាម ១,០៧៣នាក់ ស្រី ២៦៦នាក់, ជប៉ុន ៦៣៣នាក់ ស្រី ១៦៨នាក់, អូស្ត្រាលី ៤០១នាក់ ស្រី ១៨៩, នូវែលហ្សេឡង់ ២៥៨នាក់ ស្រី ១១១នាក់, ឡាវ ១០៩នាក់ ស្រី ៣៧ នាក់, សហព័ន្ធរុស្ស៊ី ៩៦នាក់ ស្រី២៣នាក់, ហុងគ្រី ១២៨នាក់ ស្រី ៤៩នាក់, អង់គ្លេស ៩៩ នាក់ ស្រី ៣៥នាក់, ឥណ្ឌូនេស៊ី ៧៥នាក់ ស្រី២២នាក់, សាធារណរដ្ឋឆែក ៥៤នាក់ ស្រី ២៣ នាក់, ហ្វីលីពីន ២៥នាក់ ស្រី៦នាក់, សឹង្ហបុរី ៣២នាក់ ស្រី ១១នាក់, គុយបា ៨នាក់, បារាំង ២៧ នាក់ ។

និស្សិតអាហារូបករណ៍បរទេសមករៀននៅគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា មានចំនួន ១,៤០៨នាក់ ស្រី ៥៥០នាក់ ក្នុងនោះ វៀតណាម ៨២១នាក់ ស្រី ២៤៥នាក់, ឡាវ ៤៦២នាក់ ស្រី ១៨៥នាក់ និងចិន ១២៥ នាក់ ស្រី១២០នាក់។

## ៣. ការឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ និងទិសដៅអនាគត

ដើម្បីឆ្លើយតបនឹងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាល នៅត្រង់បញ្ចកោណទី ៥ ស្ដីពី «បច្ចេកវិទ្យាឌីជីថល» ក៏ដូចជាការឆ្លើយតបទៅនឹងបដិវត្ត ឧស្សាហកម្មទី ៤ និងបរិវត្តកម្មឌីជីថលនៃសេដ្ឋកិច្ច និងសង្គមកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាបានគាំទ្រសាកលវិទ្យាល័យជាតិគ្រប់គ្រង ក្នុងការបង្កើត និងអភិវឌ្ឍមហាវិទ្យាល័យសេដ្ឋកិច្ចបច្ចេកវិទ្យាឌីជីផល ស្របតាមនិន្នាការសេដ្ឋកិច្ច និងសង្គមឌីជីថល។ ដំណើរការរៀបចំអភិវឌ្ឍទីតាំងគិតមកដល់ពេលនេះ មានរយៈពេល៥ឆ្នាំ ដោយសម្រេចបានដំហានទី១ និងបានប្រើប្រាស់ថវិកាប្រមាណ ៦ លានដុល្លារ ក្នុងនោះរួមមានការរៀបចំអភិវឌ្ឍផ្នែករឹង ហេដ្ឋារចនាសម្ពន្ធ័រូបវន្ត និងផ្នែកទន់ ការរៀបចំអភិវឌ្ឍកម្មវិធីសិក្សាថ្មីៗស្របតាមនិន្នាការថ្មី។

**ខាងផ្នែកបច្ចេកវិទ្យា** វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាបានបង្កើតកម្មវិធីបណ្ដុះបណ្ដាលលើមុខជំនាញថ្មីៗថ្នាក់បណ្ឌិត អនុបណ្ឌិត វិស្វករ និងថ្នាក់បរិញ្ញាបត្ររង និងបានបង្កើតកម្មវិធីសិក្សា ដើម្បីបណ្ដុះបណ្ដាលលើជំនាញថ្មីៗ ដូចជា វិស្វកម្មវិទ្យាសាស្ត្រទិន្នន័យ ដឹកជញ្ជូននិងហេដ្ឋារចនាសម្ព័ន្ធ ប្រព័ន្ធបញ្ញានិងបណ្ដាញអគ្គិសនី មេកាត្រូនិច អេឡិចត្រូនិច កែច្នៃ និងវិភាគអាហារ។ ក្រៅពីនេះ វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជាក៏បានរៀបចំកម្មវិធីសិក្សាអន្តរជាតិ ខាងផ្នែកវិស្វកម្ម software បញ្ញាសប្បនិម្មិត (AI) និងសន្តិសុខសាយប័រ (Cyber Security) រ៉ូបូទិចនិងស្វ័យប្រវត្តិកម្ម ឧស្សាហកម្មនិងគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់ និរន្តរភាព និងធុរកិច្ច និងវិទ្យាសាស្ត្ររូបធាតុ ក្រោមកិច្ចសហប្រតិបត្តិការជាមួយសាកលវិទ្យាល័យនៅប្រទេសបារាំង (ECAM LaSalle) និងប្រទេស អូស្ត្រាលី (Curtin University) តាមរូបភាព double degree program 1+3 និង articulation program 2+3 ហើយកម្មវិធីទាំងអស់នោះត្រូវបង្រៀនជាភាសាអង់គ្លេស។

**ខាងផ្នែកការសិក្សាស្រាវជ្រាវ និងនវានុវត្តន៍** (R&D and Innovation) គ្រឹះស្ថានឧត្តមសិក្សារដ្ឋ បានបង្កើតមជ្ឈមណ្ឌលឧត្តមភាព (Center of Excellence) បានចំនួន៤ ដើម្បីបណ្ដុះបណ្ដាលសហគ្រិនវ័យក្មេង និងលើកទឹកចិត្តក្នុងការបង្កើតអាជីវកម្មដោយខ្លួនឯង ព្រមទាំងអភិវឌ្ឍសមត្ថភាពអ្នកស្រាវជ្រាវវ័យក្មេងបានចំនួន ២៥០នាក់។ ទន្ទឹមនឹងលទ្ធផលសម្រេចបានគួរឱ្យកត់សម្គាល់ខាងលើ អនុវិស័យឧត្តមសិក្សានៅជួបប្រទះបញ្ហាប្រឈមមួយចំនួនខាងផ្នែកគុណភាពនៃការបណ្ដុះបណ្ដាល ជាពិសេសនៅថ្នាក់បណ្ឌិតកង្វះធនធានរូបវន្ត និងកង្វះមូលនិធិសម្រាប់ការស្រាវជ្រាវ។

ដូចនេះ ដើម្បីធានាបាននូវការបណ្តុះបណ្តាលធនធានមនុស្សប្រកបដោយគុណភាព សម្រាប់បម្រើដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ក្រសួងបានដាក់ចេញនូវផែនការកំណែទម្រង់អនុវិស័យឧត្តមសិក្សា សម្រាប់អាណត្តិទី៧ នៃរាជរដ្ឋាភិបាល ដូចមានក្នុងសេចក្តីសង្ខេបខាងក្រោម៖

**១. ការបង្កើតមជ្ឈមណ្ឌលឧត្តមភាពនៅគ្រឹះស្ថានឧត្តមសិក្សា**

- រៀបចំបង្កើតមជ្ឈមណ្ឌលឧត្តមភាពកម្រិតគ្រឹះស្ថានសិក្សា និងកម្រិតកម្មវិធីនៅតាមគ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពលស្របតាមបដិវត្តន៍ឧស្សាហកម្ម៤.០តាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធរួមមាន អគារសិក្សា អន្តេវាសិកដ្ឋាន មន្ទីរពិសោធន៍ កសិដ្ឋាន និងមជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថល
- ពង្រឹងតួនាទីយុទ្ធសាស្ត្ររបស់គ្រឹះស្ថានឧត្តមសិក្សា ដោយជំរុញវប្បធម៌កសាងឧត្តមភាព ដូចជាការជ្រើសរើស និងរក្សាទុកអ្នកមានសមត្ថភាព ការបង្កើតនវានុវត្តន៍ ការចែករំលែកលទ្ធផលស្រាវជ្រាវ និងចំណេះដឹងថ្មីៗ និងជំរុញការចូលរួមសហការអន្តរអង្គភាព។

**២. ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពស្ថាប័ន**

- កែលម្អ និងពង្រឹងប្រសិទ្ធភាពការអនុវត្តប្រព័ន្ធធានាគុណភាពផ្ទៃក្នុង ប្រព័ន្ធគ្រប់គ្រងការស្រាវជ្រាវ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ ប្រព័ន្ធគ្រប់គ្រងធនធានមនុស្ស ប្រព័ន្ធអភិបាលកិច្ច ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ និងប្រព័ន្ធគ្រប់គ្រងការសិក្សា ដោយប្រើប្រាស់បច្ចេកវិទ្យាឌីជីថល
- កែលម្អ និងបន្តអនុវត្តការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ដើម្បីផ្តល់ការទទួលស្គាល់គុណភាពអប់រំ
- ផ្តល់ការគាំទ្រដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកសាងផែនការយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយ និងការរៀបចំផែនទីបង្ហាញផ្លូវ សម្រាប់រយៈពេល១០ឆ្នាំ ដើម្បីផលិតមូលធនមនុស្សស្របតាមយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល
- ពង្រឹងគណនេយ្យភាព និងបន្តផ្តល់ស្វ័យភាពបន្ថែមដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការគ្រប់គ្រងអង្គភាព រួមមានកិច្ចការទូទៅ ការងារធនធានមនុស្ស ការសិក្សា និងការងារហិរញ្ញវត្ថុ

- រៀបចំយន្តការបញ្ចូលក្នុងក្របខ័ណ្ឌ និងរក្សាទុកបុគ្គលមានសមត្ថភាព ទេពកោសល្យ និងសញ្ញាបត្រថ្នាក់បណ្ឌិត រួមទាំងការបង្កើតកម្មវិធីថ្នាក់ក្រោយបណ្ឌិត ដើម្បីបម្រើការនៅតាមគ្រឹះស្ថានឧត្តមសិក្សា
- វិនិយោគបន្ថែមលើកម្មវិធីពង្រឹងសមត្ថភាពមន្ត្រីដឹកនាំ គ្រប់គ្រង និងជំនាញ ដោយជំរុញបន្តការសិក្សាលើជំនាញពាក់ព័ន្ធនឹងការងារ ទាំងរយៈពេលខ្លី និងវែង
- អនុវត្តប្រព័ន្ធវាយតម្លៃការអនុវត្តការងារផ្អែកលើសមិទ្ធកម្ម។

## ៣. ការធ្វើទំនើបកម្ម និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីសិក្សា

- ធ្វើទំនើបកម្ម និងការអភិវឌ្ឍកម្មវិធីសិក្សា ដោយផ្អែកលើលទ្ធផល (Outcome-Based Education Program–OBE) រួមទាំងការផ្តល់សិទ្ធិដល់គ្រឹះស្ថានឧត្តមសិក្សា ក្នុងការកែសម្រួល និងការអនុវត្តកម្មវិធីសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ការបញ្ចូលមុខវិជ្ជាថ្មីៗ និងការបង្កើតកម្មវិធីសិក្សាជំនាញថ្មី ដើម្បីឆ្លើយតបទៅនឹងការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និងបដិវត្តន៍ឧស្សាហកម្ម៤.០
- ពង្រឹងគុណភាពការបណ្តុះបណ្តាលលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម គណិតវិទ្យា និងកសិកម្ម ព្រមទាំងកម្មវិធីអាទិភាពដ៏ទៃទៀត ស្របតាមស្តង់ដាជាតិ និងអន្តរជាតិ
- បន្តអនុវត្តគំរូកម្មវិធីបណ្តុះបណ្តាល ដោយមានសហការជាមួយវិស័យឧស្សាហកម្ម និងសាកលវិទ្យាល័យជាតិនិងអន្តរជាតិ ជាលក្ខណៈ Tailor-Made ឬ Dual Education Programs ដើម្បីឆ្លើយតបនឹងនិន្នាការបច្ចុប្បន្ន និងតម្រូវការទីផ្សារការងារ
- រៀបចំគំរូកម្មវិធីសិក្សា ដែលផ្តោតលើការសិក្សាគម្រោង និងការស្រាវជ្រាវ និងបន្សុីស្តង់ដានៃការវាយតម្លៃលទ្ធផលសិក្សា ជាមួយកម្មវិធីសិក្សា និងសៀវភៅសិក្សាគោល
- បន្តជំរុញការបង្កើត និងអនុវត្តប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System–LMS) ដើម្បីបង្កើនប្រសិទ្ធភាពនៃការសិក្សា ដោយការប្រើប្រាស់ធនធានសិក្សារួម ការតាមដាននិងការវាយតម្លៃ និងការឆ្លើយតបទៅនឹងភាពបត់បែននៃពេលវេលាសិក្សារបស់និស្សិត ក៏ដូចជាកាត់បន្ថយបញ្ហាកង្វះខាតធនធានសិក្សា និងបន្ទុកចំណាយផ្សេងៗ
- រៀបចំស្តង់ដា និងឧបករណ៍សម្រាប់ការវាយតម្លៃទទួលស្គាល់គុណភាពកម្មវិធីសិក្សាលើកម្មវិធីសិក្សាសំខាន់ៗរបស់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីពង្រឹងគុណភាពការសិក្សា និងប្រើប្រាស់ជាយន្តការ ក្នុងការទទួលស្គាល់ការផ្ទេរក្រេឌីតការសិក្សាក្នុងចំណោមគ្រឹះស្ថាន

ឧត្តមសិក្សា ឆ្ពោះទៅការកាត់បន្ថយអត្រាបោះបង់ការសិក្សា និងដើម្បីបង្កភាពងាយស្រួលដល់ការសិក្សាពេញមួយជីវិតរបស់និស្សិត

- ពង្រឹងនិងពង្រីកវិសាលភាពការអនុវត្តបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា ជាមួយគ្រឹះស្ថានឧត្តមសិក្សាគោលដៅ ទាំងក្នុងរាជធានីភ្នំពេញ និងនៅតាមបណ្តាខេត្ត ដើម្បីលើកកម្ពស់ការប្រើប្រាស់ធនធានរួមគ្នា តាមរយៈការអប់រំឌីជីថល
- វិនិយោគបន្ថែម ដើម្បីធ្វើឱ្យប្រសើរឡើងនូវមន្ទីរពិសោធន៍ កសិដ្ឋាន អន្តេវាសិកដ្ឋាន និងមជ្ឈមណ្ឌលបច្ចេកវិទ្យាឌីជីថល ក្នុងគ្រឹះស្ថានសិក្សាដែលមានសក្តានុពល ដើម្បីប្រែក្លាយគ្រឹះស្ថានសិក្សាទាំងនោះឱ្យមានកម្រិតស្តង់ដាអន្តរជាតិ និងប្រែក្លាយជាមជ្ឈមណ្ឌលធនធាន សម្រាប់ប្រើប្រាស់រួមគ្នា។

## ៤. ការផ្តោតលើការពង្រឹងអន្តរភាវូបនីយកម្មនៃការអប់រំឧត្តមសិក្សា

- បង្កើត និងអនុវត្តកម្មវិធីសិក្សាអន្តរជាតិ រួមមាន កម្មវិធីសិក្សាភ្លោះ ឬកម្មវិធីសិក្សារួមគ្នា ជាពិសេសសម្រាប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត តាមរយៈការសហការជាមួយសាកលវិទ្យាល័យ និងក្រុមហ៊ុនឧស្សាហកម្មដៃគូទាំងនៅក្នុង និងក្រៅប្រទេស
- លើកកម្ពស់ការផ្លាស់ប្តូរគ្រូបង្រៀន អ្នកស្រាវជ្រាវ និងនិស្សិត រវាងសាកលវិទ្យាល័យនៅកម្ពុជា និងសាកលវិទ្យាល័យដៃគូអន្តរជាតិ
- ជំរុញការអនុវត្តគម្រោងស្រាវជ្រាវរួមគ្នា ជាមួយបណ្តាសាកលវិទ្យាល័យដៃគូនៅក្រៅប្រទេស
- គាំទ្រផ្នែកហិរញ្ញវត្ថុដល់គ្រឹះស្ថានឧត្តមសិក្សា ដើម្បីអញ្ជើញសាស្ត្រាចារ្យ និងអ្នកជំនាញពីបរទេសមកជួយបង្រៀនមុខវិជ្ជាថ្មីៗ ឆ្ពោះទៅរកការពង្រឹងគុណភាពនៃការសិក្សាជាពិសេសនៅថ្នាក់ក្រោយបរិញ្ញាបត្រ។

## ៥. ការផ្តោតលើការពង្រឹងប្រសិទ្ធភាពនៃការបង្រៀន និងរៀន

- បង្កើនចំនួនគ្រូបង្រៀនថ្នាក់បណ្ឌិតលើជំនាញអាទិភាព ដែលជាតម្រូវការជាតិ និងពង្រឹងគុណភាពគ្រូបង្រៀន
- អនុវត្តវិធីសាស្ត្របង្រៀនទំនើប ដើម្បីលើកកម្ពស់បំណិនសតវត្សទី២១ ជាមួយប្រព័ន្ធនៃការសិក្សាតាមបែបចម្រុះ (Blended Learning) និងផ្សារភ្ជាប់ជាមួយប្រព័ន្ធគ្រប់គ្រងការសិក្សា (Learning Management System)

- ជំរុញការបង្រៀនតាមបែបសិក្សាគម្រោង (អនុវត្តផ្ទាល់ក្នុងមន្ទីរពិសោធន៍ កសិដ្ឋាន ឬជាក្រុម) និងលើកកម្ពស់ការបង្រៀនភាសាបរទេស បំណិនសហគ្រិនភាព បំណិនបច្ចេកវិទ្យា និងបំណិនឌីជីថល
- រៀបចំយន្តការជំរុញការសិក្សាគម្រោង ការស្រាវជ្រាវ ពិសោធន៍ ចុះកម្មសិក្សា និងការចល័តនិស្សិតជាមួយសាកលវិទ្យាល័យអន្តរជាតិ ស្ថាប័នដៃគូ និងផ្នែកឧស្សាហកម្ម
- រៀបចំយន្តការការបង្កើតក្លឹបសិក្សា និងស្វ័យសិក្សា និងការជួយនិស្សិតរៀនយឺត។

## ៦. ការពង្រឹងប្រព័ន្ធអេកូឡូស៊ីស្រាវជ្រាវនៅឧត្តមសិក្សា

- ជំរុញសកម្មភាពស្រាវជ្រាវ និងអភិវឌ្ឍនវានុវត្តន៍នៅតាមគ្រឹះស្ថានឧត្តមសិក្សាដោយរៀបចំផ្តល់មូលនិធិស្រាវជ្រាវ និងគោលការណ៍ឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ដើម្បីគាំទ្រដល់ការងារស្រាវជ្រាវរបស់និស្សិត (សារណា/និក្ខេបបទ) និងកសាងថ្នាលអ្នកស្រាវជ្រាវវ័យក្មេង និងអ្នកស្រាវជ្រាវអាជីពឱ្យមានសមត្ថភាពបោះពុម្ពអត្ថបទស្រាវជ្រាវក្នុងទស្សនាវដ្តីស្រាវជ្រាវ កម្រិតជាតិ និងអន្តរជាតិ
- ផ្សារភ្ជាប់ការស្រាវជ្រាវទៅនឹងសាលាក្រោយឧត្តម ដោយជំរុញឱ្យមានការចូលរួមការអនុវត្តការងារ ស្រាវជ្រាវពីនិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត និងមានការប្រើប្រាស់លទ្ធផលស្រាវជ្រាវ ដើម្បីកែលម្អកម្មវិធីសិក្សា និងវិធីសាស្ត្របង្រៀន
- កសាងបណ្តាញអ្នកស្រាវជ្រាវក្នុងចំណោមគ្រឹះស្ថានឧត្តមសិក្សា ដោយមានកិច្ចសហការពីវិស័យឯកជន ដើម្បីស្រាវជ្រាវលើប្រធានបទច្បាស់លាស់ និងអភិវឌ្ឍនវានុវត្តន៍ ដែលឆ្លើយតបទៅនឹងទីផ្សារ និងការងារអាទិភាពរបស់រាជរដ្ឋាភិបាល
- ជំរុញការបង្កើតទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រតាមជំនាញ ឬឯកទេស ដើម្បីផ្សព្វផ្សាយលទ្ធផលទទួលបានពីការស្រាវជ្រាវ ដល់អ្នកដែលពាក់ព័ន្ធ
- អភិវឌ្ឍស្តង់ដាទស្សនាវដ្តីស្រាវជ្រាវរបស់ក្រសួង និងគ្រឹះស្ថានឧត្តមសិក្សា ដែលមានសក្តានុពលឱ្យទទួលបានស្តង់ដាអាស៊ាន និងអន្តរជាតិ
- ជំរុញការប្រើប្រាស់យន្តការការចុះជួយដឹកដៃ ដើម្បីលើកកម្ពស់សមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សា
- ជំរុញការផ្សព្វផ្សាយស្នាដៃស្រាវជ្រាវ តាមរយៈការរៀបចំវេទិកាចែករំលែកឧត្តមានុវត្តន៍ បទពិសោធន៍ និងលទ្ធផលស្រាវជ្រាវ

- ពង្រឹងយន្តការលើកទឹកចិត្តអ្នកស្រាវជ្រាវ តាមរយៈការរៀបចំឋានៈអ្នកស្រាវជ្រាវ និងផ្តល់ឋានៈសាស្ត្រាចារ្យ ការទទួលស្គាល់លទ្ធផលស្រាវជ្រាវ និងការវាយតម្លៃការងារផ្អែកលើស្នាដៃស្រាវជ្រាវ
- បង្កើតសង្គមវិទ្យាសាស្ត្រ (Professional Scientific Society) ដើម្បីផ្តល់ឱកាសឱ្យអ្នកសិក្សាស្រាវជ្រាវ និស្សិត និងអ្នកឯកទេស ឬអ្នកជំនាញដែលមានជំនាញឯកទេសដូចគ្នា ឬប្រហាក់ប្រហែលគ្នា អាចចងក្រងជាសហគមន៍ ដើម្បីចែករំលែកបទពិសោធន៍ និងឧត្តមានុវត្តន៍ តាមរយៈការរៀបចំសិក្ខាសាលា សន្និសីទប្រចាំឆ្នាំ វគ្គបណ្តុះបណ្តាល ការបោះពុម្ពសៀវភៅ និងអត្ថបទបច្ចេកទេស
- ជំរុញការបង្កើតភាពជាដៃគូរវាងសាកលវិទ្យាល័យ និងសាកលវិទ្យាល័យ (Consortium Universities) សាកលវិទ្យាល័យ និងក្រុមហ៊ុនឧស្សាហកម្មឯកជន (University-Industry Linkage) សាកលវិទ្យាល័យ និងសហគមន៍ (University-Community Partnership) ដើម្បីអនុវត្តគម្រោងស្រាវជ្រាវលើប្រធានបទសំខាន់ៗ ឆ្លើយតបនឹងតម្រូវការសង្គមជាតិ
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាបញ្ញាសិប្បនិម្មិត ក្នុងចំណោមសាស្ត្រាចារ្យ និងនិស្សិត ក្នុងគោលបំណងជួយដល់ការងារស្រាវជ្រាវ តាមរយៈវេទិកាចែករំលែកចំណេះដឹងតាមប្រព័ន្ធអនឡាញ និងដោយផ្ទាល់។

### ៧. ការផ្តោតលើការបង្កើនចំនួននិស្សិតចូលរៀន និងបរិយាប័ន្ន

- ពង្រីកការអនុវត្តកម្មវិធីភាពជាដៃគូការអប់រំស្ទែម តាមគំរូភាពជាដៃគូរវាងមធ្យមសិក្សានិងឧត្តមសិក្សា ដើម្បីលើកកម្ពស់សមត្ថភាពសិស្សានុសិស្ស និងលទ្ធភាពបន្តការសិក្សានៅឧត្តមសិក្សា
- ពង្រីកការអនុវត្តគោលនយោបាយអាហារូបករណ៍ សម្រាប់និស្សិតក្រីក្រមកពីជនបទ និងមានពិការភាព ជាពិសេសអនុវត្តមូលនិធិសមធម៌ ជាមួយសហគមន៍ និងវិស័យឯកជនឱ្យបានកាន់តែទូលំទូលាយ ដើម្បីគាំទ្រថវិកាសម្រាប់និស្សិតចូលរៀននៅឧត្តមសិក្សា។

## ៤. ការបង្កើតបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា

ការបង្កើតបណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជា (ប.ស.ស.ក) មានគោលបំណង៖ ទី១).បន្តនិរន្តរភាពនៃការបណ្តុះបណ្តាលនៅកម្រិតឧត្តមសិក្សា ក្នុងអំឡុងពេលនៃការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ និងក្រោយពេលមានវិបត្តិ, ២).ពង្រឹងគុណភាពនៃការបណ្តុះបណ្តាល

នៅកម្រិតឧត្តមសិក្សា ដោយប្រើប្រាស់នូវថ្នាលអបរំឌីជីថលរួមគ្នា និងចែករំលែកការប្រើប្រាស់ឱ្យអស់លទ្ធភាពនូវធនធានហេដ្ឋារចនាសម្ព័ន្ធ និងធនធានសិក្សាក្នុងចំណោមសាកលវិទ្យាល័យជាសមាជិក, ៣).ផ្តល់លទ្ធភាពក្នុងការផ្ទេរឥណទានសិក្សារវាងសាកលវិទ្យាល័យជាសមាជិក និង ៤).បើកចំហធនធានសិក្សាទៅកាន់អ្នកសិក្សាក្នុងតំបន់និងសាកលលោក។

គិតចាប់ពីឆ្នាំ២០២២ រហូតដល់បច្ចុប្បន្ន បណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជាមានគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជនចំនួន ១២ បានចូលជាសមាជិក រួមមាន៖

១- វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា

២- សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

៣- សាកលវិទ្យាល័យជាតិបាត់ដំបង

៤- សាកលវិទ្យាល័យស្វាយរៀង

៥- សាកលវិទ្យាល័យ ហេង សំរិន ត្បូងឃ្មុំ

៦- សាកលវិទ្យាល័យភូមិន្ទកសិកម្ម

៧. សាកលវិទ្យាល័យជាតិគ្រប់គ្រង

៨. សាកលវិទ្យាល័យជាស៊ីមកំចាយមារ

៩. សាកលវិទ្យាល័យក្រចេះ

១០. វិទ្យាស្ថានគរុកោសល្យបាត់ដំបង

១១. សាកលវិទ្យាល័យភ្នំពេញអន្តរជាតិ និង

១២. សាកលវិទ្យាល័យអង្គរ

ដើម្បីសម្រេចគោលបំណងខាងលើនេះ បណ្តាញសាកលវិទ្យាល័យសាយប័រកម្ពុជាបានដាក់ចេញនូវផែនការសកម្មភាពរយៈពេល៣ឆ្នាំ ជា ៣ ដំណាក់កាលធំៗ ដូចខាងក្រោម៖

- ដំណាក់កាលទី១ ក្នុងឆ្នាំ២០២៣ ផ្តោតទៅលើការកសាងហេដ្ឋារចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាព ដោយក្នុងនោះសាកលវិទ្យាល័យចំនួន ៦ ដែលជាសមាជិកដំបូង បានចាប់ផ្តើមផលិត និងដំណើរការមាតិកា និងខ្លឹមសារមេរៀនតាមអនឡាញ
- ដំណាក់កាលទី២ ក្នុងឆ្នាំ ២០២៤ ផ្តោតលើការបង្កើតមេរៀនរួមគ្នា ឬកម្មវិធីរួមគ្នារវាងសាកលវិទ្យាល័យជាសមាជិក ដើម្បីផ្តល់លទ្ធភាពក្នុងការផ្ទេរឥណទានសិក្សា និង
- ដំណាក់កាលទី៣ ក្នុងឆ្នាំ ២០២៥ គឺជាការបើកចំហធនធានសិក្សារបស់កម្ពុជាទៅកាន់តំបន់ និងពិភពលោក។

គិតត្រឹមឆ្នាំ២០២៤នេះ បណ្ដាញសាកលវិទ្យាល័យសាយប័រកម្ពុជាសម្រេចបានសមិទ្ធផលការងារដូចខាងក្រោម៖

- បានបង្កើត និងកែលម្អបន្ទប់ស្ទីឌីយោសម្រាប់សាកលវិទ្យាល័យចំនួន៥
- បានតភ្ជាប់បញ្ចូលគ្នារវាងហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់សាកលវិទ្យាល័យសមាជិកចំនួន៦
- បានរៀបចំបង្កើតដូម៉ែន (domain) និងបង្កើតប្រព័ន្ធគ្រប់គ្រងការរៀន និងបង្រៀន និងបានដាក់ឱ្យដំណើរការនៅលើ moodle.ccun.edu.kh
- អភិវឌ្ឍសមត្ថភាពសាស្ត្រាចារ្យ និងបុគ្គលិកចំនួន ៥៤ នាក់ លើជំនាញផលិតមេរៀន ផលិតធនធានសិក្សាអនឡាញ ប្រព័ន្ធគ្រប់គ្រងការរៀន និងបង្រៀនតាមប្រព័ន្ធអនឡាញ និងការគ្រប់គ្រងបណ្ដាញតាមសាកលវិទ្យាល័យ។
- បានផលិតមាតិកាមេរៀនចំនួន ៦៩ មុខវិជ្ជា សម្រាប់ដាក់ឱ្យអនុវត្តកម្មវិធីសិក្សាថ្នាក់បរិញ្ញាបត្រចំនួន ១៨ ជំនាញឯកទេស និង
- បានទទួលនិស្សិតចុះឈ្មោះចូលរៀនចំនួន ៥៤៣២ នាក់។

ជាទីបញ្ចប់ តាងនាមក្រសួងអប់រំ យុវជន និងកីឡា ខ្ញុំសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះវត្តមានដ៏ថ្លៃថ្លារបស់ **សម្ដេចមហាបវរធិបតី** ព្រមទាំងលោកជំទាវបណ្ឌិត ដែលជានិច្ចកាលតែងតែយកចិត្តទុកដាក់ខ្ពស់ចំពោះវិស័យអប់រំ និងសូមប្រសិទ្ធពរ បវរមហាប្រសើរជូនចំពោះ **សម្ដេចមហាបវរធិបតី** ព្រមទាំងលោកជំទាវបណ្ឌិត សូមទទួលបាននូវ ពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ ដើម្បីជាមគ្គុទ្ទេសក៍ដ៏ប្រសើរក្នុងការស្ថាបនាកម្ពុជាឆ្ពោះទៅរកភាពរុងរឿង។

ខ្ញុំក៏សូមថ្លែងអំណរគុណនិងសូមប្រសិទ្ធពរជូនចំពោះ ឯកឧត្ដម លោកជំទាវ លោក លោកស្រី ជាភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ សូមប្រកបដោយសុខភាពល្អ ថាមពលខ្លាំងក្លា ប្រាជ្ញាវាងវៃនិងទទួលបានជោគជ័យគ្រប់ប្រការកុំបីអាក់ខានឡើយ។

ខ្ញុំបាទមានកិត្តិយស សូមអនុញ្ញាតគោរពអញ្ជើញ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាមានមតិសំណេះសំណាល ណែនាំ និងផ្ដល់អនុសាសន៍ដល់អង្គពិធីទាំងមូល ដោយសេចក្ដីគោរពដ៏ខ្ពង់ខ្ពស់បំផុត។

**សូមគោរពអញ្ជើញ!**